ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៧៤០ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**វិធាន និងនីតិវិធីនៃការធ្វើនិត្យានុកូលកម្មលិខិតគតិយុត្ត**
**បង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃ ទី១៨ ខែ សីហា ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសារាចររបស់រាជរដ្ឋាភិបាលលេខ ០៤ សរ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២៣ ស្ដីពីការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ
- យោងតាមតម្រូវការចាំបាច់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ កំណត់ អំពីវិធាន និងនីតិវិធីនៃការធ្វើនីត្យានុកូលកម្មឡើងវិញ នូវរាល់លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ក្នុងគោលបំណងធានា នូវសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ និងអនុលោមភាពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីធានាប្រសិទ្ធភាព សក្ដិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព លើការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ។

**ប្រការ ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធទាំងឡាយដែលបានបង្កើត ឬបានកែប្រែ ដោយក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ នីតិបុគ្គលសាធារណៈដទៃទៀត និងភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ÷

- មិនទទួលបានការពិនិត្យ និងឯកភាព របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រគល់សិទ្ធិស្របច្បាប់ ឬ
- វិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈមកលើភាគីរដ្ឋ ឬ
- ទិដ្ឋភាពផ្នែកហិរញ្ញវត្ថុសាធារណៈមិនអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍សម្រេច របស់រាជរដ្ឋាភិបាល។

ប្រការ ៣.-

វាក្យសព្ទ ដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម÷

- **ការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធឡើងវិញ ឬការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត** សំដៅដល់ការពិនិត្យ និងការរៀបចំឡើងវិញ នូវលិខិតគតិយុត្ត ដែលមិនទទួលបានការពិនិត្យ និងឯកភាព របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រគល់សិទ្ធិស្របច្បាប់ ឬលិខិតគតិយុត្ត ដែលវិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ ឬលិខិតគតិយុត្ត ដែលមិនអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងគោលការណ៍សម្រេច របស់រាជរដ្ឋាភិបាល។
- **ភាគីនៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬភាគីនៃលិខិតគតិយុត្ត** សំដៅដល់បុគ្គល ដែលបានចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ឬបុគ្គល ដែលទទួលបានសិទ្ធិពីរដ្ឋ ដើម្បីធ្វើអាជីវកម្ម វិនិយោគ សម្បទាន តាមរយៈកិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងលិខិតគតិយុត្តផ្សេងទៀត។
- **លិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ឬលិខិតគតិយុត្ត** សំដៅដល់កិច្ចសន្យា កិច្ចព្រមព្រៀង សៀវភៅបន្ទុក អាជ្ញាបណ្ណ លិខិតអនុញ្ញាត និងលិខិតគតិយុត្តផ្សេងទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។
- **វិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ** សំដៅដល់លក្ខខណ្ឌហិរញ្ញវត្ថុនៃលិខិតគតិយុត្ត ដែលបានកំណត់ពីថ្លៃឈ្នួល ឬថ្លៃសម្បទាន ឬភាគចំណែករបស់រដ្ឋ ឬកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត ដែលរដ្ឋត្រូវទទួលបានមានតម្លៃទាបមិនសមស្របទៅនឹងតម្លៃទីផ្សារ និងស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង។
- **អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងគ្រប់គ្រង តាមដាន និងត្រួតពិនិត្យលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។
- **អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី ២

## លិខិតគតិយុត្តជាកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្ម

**ប្រការ ៤.-**

ប្រភេទនៃលិខិតគតិយុត្ត ដែលស្ថិតក្នុងកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្ម មានជាអាទិ៍÷

ក. កិច្ចសន្យា÷

- កិច្ចសន្យាជួលដីទំនេរ
- កិច្ចសន្យាជួលដី និងអគារ
- កិច្ចសន្យាជួលអគារ ឬសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ
- កិច្ចសន្យាជួលសម្ភារៈបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ
- កិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋជាចលនទ្រព្យ និងអចលនទ្រព្យដទៃទៀត
- កិច្ចសន្យាជួលកោះ
- កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- កិច្ចសន្យាសម្បទានធនធានធម្មជាតិ
- កិច្ចសន្យាអនុវត្តអាជ្ញាបណ្ណ ឬសៀវភៅបន្ទុក ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ
- កិច្ចសន្យាផ្សេងៗទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

ខ. កិច្ចព្រមព្រៀង÷

- កិច្ចព្រមព្រៀងប្រេងកាត
- កិច្ចព្រមព្រៀងគម្រោងថាមពលអគ្គិសនី
- កិច្ចព្រមព្រៀងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- កិច្ចព្រមព្រៀងទ្វេភាគី ជាមួយភាគីឯកជនដទៃទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

គ. សៀវភៅបន្ទុកសម្បទានគ្រប់គ្រងសេវាសាធារណៈ÷

- ផ្សារ
- កំពង់ចម្លង
- ចំណតយានជំនិះ
- ចំណតជលយាន

- មជ្ឈមណ្ឌលបែងចែកផលនេសាទ
- សត្តឃាតដ្ឋាន
- អនាម័យសត្វ
- ទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន
- ស្ថានីយផ្ទេរសំរាមសំណល់រឹងទីប្រជុំជន
- សេវាអនាម័យ
- ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ
- សៀវភៅបន្ទុកសម្បទានដទៃទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

**ឃ. អាជ្ញាបណ្ណ÷**

អាជ្ញាបណ្ណតាមវិស័យមានជាអាទិ៍ វិស័យរ៉ែ និងថាមពល វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ វិស័យទេសចរណ៍ និងវិស័យផ្សេងទៀត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

**ង. លិខិតអនុញ្ញាត÷**

លិខិតអនុញ្ញាត ដែលចេញដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជូនរូបវន្តបុគ្គល ឬនីតិបុគ្គល ដើម្បីបំពេញកិច្ចការអ្វីមួយ ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ ឬកំណត់ អំពីកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ។

**ប្រការ ៥.-**

លិខិតគតិយុត្ត ដែលជាកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្ម គឺជាលិខិតគតិយុត្តទាំងឡាយណា ដែលស្ថិតក្នុងលក្ខខណ្ឌវិនិច្ឆ័យណាមួយ ដូចខាងក្រោម÷

- លិខិតគតិយុត្ត ដែលមិនទទួលបានការពិនិត្យ និងឯកភាព របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រគល់សិទ្ធិស្របច្បាប់
- លិខិតគតិយុត្ត ដែលកែសម្រួល ឬធ្វើវិសោធនកម្ម ឬផ្ទេរមួយផ្នែក ឬទាំងស្រុង នូវសិទ្ធិ និងកាតព្វកិច្ច ដូចមានកំណត់ ក្នុងលិខិតគតិយុត្ត ដោយពុំមានការពិនិត្យ និងឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតគតិយុត្ត ដែលមានវិសមធម៌ផ្នែកហិរញ្ញវត្ថុសាធារណៈ ចំពោះភាគីរដ្ឋ
- លិខិតគតិយុត្ត ដែលទិដ្ឋភាពផ្នែកហិរញ្ញវត្ថុសាធារណៈមិនមានអនុលោមភាពជាមួយនឹងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន និងគោលការណ៍សម្រេច របស់រាជរដ្ឋាភិបាល។

ប្រការ ៦.-

ការអនុវត្តវិធាន ដែលជាកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ដូចមានចែងនៅក្នុងប្រការ ៤ និងប្រការ ៥ ត្រូវអនុលោមតាមប្រភេទ និងលក្ខខណ្ឌនៃលិខិតគតិយុត្ត ដែលសម្រេចដោយរាជរដ្ឋាភិបាល។

## ជំពូកទី ៣
## បែបបទ និងនីតិវិធីនៃការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត

ប្រការ ៧.-

ការងារធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ត្រូវបានអនុវត្ត តាមរយៈយន្តការគណៈកម្មការអន្តរក្រសួង ស្ថាប័ន ហៅថា "គណៈកម្មការ" ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានលេខាធិការដ្ឋាន ជាសេនាធិការ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការអន្តរក្រសួង ស្ថាប័ន ត្រូវកំណត់ដោយលិខិតបទដ្ឋាន គតិយុត្តដោយឡែក។

ប្រការ ៨.-

គណៈកម្មការ និងលេខាធិការដ្ឋាន នឹងត្រូវរំសាយវិញ នៅពេលការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ត្រូវបានបញ្ចប់ជាស្ថាពរ។

ប្រការ ៩.-

គណៈកម្មការ ត្រូវកំណត់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋប្រគល់លិខិតគតិយុត្ត ដែលជាកម្មវត្ថុ នៃការធ្វើនីត្យានុកូលកម្មឡើងវិញមកគណៈកម្មការ ដោយត្រូវកំណត់នូវរយៈពេលច្បាស់លាស់ ក្នុងការប្រគល់ លិខិតគតិយុត្ត គិតចាប់ពីពេលទទួលបានលិខិតស្នើសុំ របស់គណៈកម្មការ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវប្រគល់លិខិតគតិយុត្តទាំងអស់ ដែលជាកម្មវត្ថុនៃការធ្វើនីត្យា-នុកូលកម្មមក គណៈកម្មការ ដោយភ្ជាប់ជាមួយនឹងបញ្ជីរាយនាមឱ្យបានច្បាស់លាស់ ដើម្បីពិនិត្យ និងរៀបចំ ធ្វើនីត្យានុកូលកម្ម ផ្អែកតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

ប្រការ ១០.-

បន្ទាប់ពីទទួលបានលិខិតគតិយុត្ត ដែលជាកម្មវត្ថុនៃការធ្វើនីត្យានុកូលកម្ម ពីអាជ្ញាធរកាន់កាប់ទ្រព្យ សម្បត្តិរដ្ឋរួច គណៈកម្មការ ត្រូវរៀបចំពិនិត្យ និងបំពេញការងារនៃការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តឱ្យ បានទាន់ពេលវេលា និងមានប្រសិទ្ធភាពទៅតាមតួនាទី និងភារកិច្ចរបស់ខ្លួន។

**ប្រការ ១១.-**

គណៈកម្មការ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីលទ្ធផលនៃការព្រមព្រៀងគ្នារវាង គណៈកម្មការ និងភាគីនៃលិខិតគតិយុត្ត ក្នុងការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ដើម្បីមានមូលដ្ឋានស្នើសុំការពិនិត្យ និងសម្រេចជាចុងក្រោយ ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ១២.-**

លិខិតគតិយុត្ត ដែលបានធ្វើនីត្យានុកូលកម្មរួចរាល់ ត្រូវរក្សាទុកចំនួន ០១ (មួយ) ច្បាប់ នៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ស្ថាប័នតុលាការ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- ភាគីនៃលិខិតគតិយុត្ត
- អង្គភាពពាក់ព័ន្ធដទៃទៀត ។

**ប្រការ ១៣.-**

រាល់លិខិតរដ្ឋបាល និងសំណុំឯកសារ ដែលត្រូវប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការងារធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ដូចមានកំណត់ក្នុងប្រកាសនេះ ត្រូវមានចុះហត្ថលេខា និងបោះត្រា របស់សាមីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី ៤
## ការដោះស្រាយវិវាទ

**ប្រការ ១៤.-**

ក្នុងករណីមានវិវាទកើតឡើងពាក់ព័ន្ធនឹងការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើការចរចា និងដោះស្រាយជាមួយភាគីនៃលិខិតគតិយុត្ត ដោយឈរលើស្មារតីសម្របសម្រួលស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

គណៈកម្មការ ចូលរួមដោះស្រាយវិវាទ តាមសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ។

**ប្រការ ១៥.-**

ក្នុងករណីដោះស្រាយពុំទទួលបានជោគជ័យ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងគណៈកម្មការ ត្រូវសហការរៀបចំប្រមូលសំណុំឯកសារពាក់ព័ន្ធ ដើម្បីបន្តនីតិវិធីស្នើសុំការសម្រេច ពីរាជរដ្ឋាភិបាល។

## ជំពូកទី ៥
## ការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម

**ប្រការ ១៦.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ គណៈកម្មការ និងលេខាធិការដ្ឋាន ព្រមទាំងភាគីពាក់ព័ន្ធ ដែលបានចូលរួមបំពេញការងារធ្វើនីត្យានុកូលកម្ម ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់ ត្រូវទទួលបានការលើកទឹកចិត្ត តាមការសម្រេច របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការលើកទឹកចិត្ត មានរូបភាពជាអាទិ៍ ÷

- ការបង្កើនភាគរយប្រាក់រង្វាន់ ដែលទទួលបាន ពីការប្រមូលចំណូលមិនមែនសារពើពន្ធបានចំនួនច្រើនលើសការអនុវត្តកន្លងមក តាមរយៈការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត
- ការផ្តល់ប័ណ្ណសរសើរ និងគ្រឿងឥស្សរិយយស
- ការផ្តល់ជាថវិកាលើកទឹកចិត្ត។

**ប្រការ ១៧.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលមិនចូលរួមសហការពេញលេញ ក្នុងការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្ត ស្របតាមវិធាន និងនីតិវិធី ដែលមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងការចាត់វិធានការរឹតត្បិត តាមការសម្រេច របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានជាអាទិ៍÷

- កាត់បន្ថយចំនួនភាគរយនៃប្រាក់រង្វាន់ ដែលទទួលបាន ពីការប្រមូលចំណូលមិនមែនសារពើពន្ធ
- កាត់បន្ថយឥណទានចំណាយប្រចាំឆ្នាំ។

ក្នុងករណី ដែលការមិនចូលរួមសហការ ក្នុងការធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តនេះប្រព្រឹត្តដោយភាគីនៃលិខិតគតិយុត្ត និងបុគ្គលពាក់ព័ន្ធផ្សេងទៀត គណៈកម្មការ ត្រូវស្នើសុំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការ ដូចខាងក្រោម÷

- បញ្ឈប់ការអនុវត្តលិខិតគតិយុត្តជាបណ្តោះអាសន្ន និង/ឬ
- រំលាយលិខិតគតិយុត្ត និង/ឬ
- ចាត់វិធានការផ្សេងទៀត ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឡើយ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

ត្រូវធ្វើនីត្យានុកូលកម្មលិខិតគតិយុត្តទាំងឡាយណា ដែលពុំមានការឯកភាព ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ១ (មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចូលជាធរមាននៃច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែន

សារពើពន្ធ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចពន្យាររយៈពេលនៃការធ្វើនីត្យានុកូលកម្មនេះបន្ថែមទៀត។

**ប្រការ ១៩.-**

រាល់លិខិតគតិយុត្តពាក់ព័ន្ធនឹងការជួលទ្រព្យសម្បត្តិរដ្ឋទាំងឡាយណា ដែលបានធ្វើឡើងមុនឆ្នាំ ២០១៥ និងមានវិសមធម៌ចំពោះរដ្ឋក្នុងការទទួលបានចំណូលពីការជួលនេះ ត្រូវមានអាទិភាពសម្រាប់ការធ្វើនីត្យានុកូលកម្ម លើលក្ខខណ្ឌពាក់ព័ន្ធនឹងការកំណត់ថ្លៃជួល តាមការសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ២០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ភាគីពាក់ព័ន្ធ នៃលិខិតគតិយុត្តបង្កើតចំណូលមិនមែនសារពើពន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦រោច ខែជេស្ឋ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ